**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**

**អភិបូជាថ្ងៃព្រហស្បត្តិ៍ពិសិដ្ឋ**

**ព្រឹកប្រស់ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩**

# ព្រះយេស៊ូអញ្ជើញខ្ញុំឲ្យខ្ញុំធ្វើជាអ្នកបម្រើ

**អត្ថបទទី១៖ សេរីភាព ១២,១-៨.១១-១៤**

ឈាមដែលអ្នករាល់គ្នាលាបនៅលើក្របទ្វារផ្ទះនឹងធ្វើជាសញ្ញាសម្គាល់ថា អ្នករាល់គ្នាស្នាក់នៅក្នុងផ្ទះនោះ។ សរ ១២,១៣

**អត្ថបទទី២៖ កូរិនថូស ទី១ ១១,២៣-២៦**

រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ។ ១ករ ១១,២៦

**ដំណឹងល្អ៖ យ៉ូហាន ១៣,១-១៥**

ខ្ញុំបានធ្វើជាគំរូឲ្យអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា។ យហ ១៣,១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយល្អ ដើម្បីចូលរួមយ៉ាងជិតស្និទ្ធនៅក្នុងពិធីជប់លៀងចុងក្រោយរបស់ព្រះយេស៊ូ។ នៅពេលនេះ យើងនឹកឃើញដល់ព្រះយេស៊ូដែលអង្គុយរួមតុជាមួយយើង ជាព្រះយេស៊ូដែលកំពុងមានព្រះបន្ទូលដល់យើងដែរ។ យើងបិទភ្នែក ដើម្បីនឹកឃើញព្រះយេស៊ូដែលកំពុងមានព្រះបន្ទូលជាមួយយើង "**នេះជារូបកាយរបស់ខ្ញុំ នេះជាព្រះលោហិតរបស់ខ្ញុំ សូមធ្វើដូច្នេះដើម្បីនឹករលឹកដល់ខ្ញុំ**" ព្រះបន្ទូលនេះ មិនមែនជាព្រះបន្ទូលដែលយើងស្តាប់២០០០ឆ្នាំមុន តែជាព្រះបន្ទូលដែលយើងស្តាប់ថ្ងៃនេះ។ យើងជាសាវ័ក យើងជាគ្រីស្តទូត យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ យើងបានធ្វើដំណើរជាមួយព្រះយេស៊ូពីប៉ុន្មានឆ្នាំហើយ។ នៅថ្ងៃនេះ ជាព្រះយេស៊ូដែលបានអញ្ជើញយើងដើម្បីជប់លៀងជាមួយព្រះអង្គ នៅពេលនេះយើងកំពុងអង្គុយរួមតុជាមួយព្រះយេស៊ូ។ យើងនឹកឃើញដល់ព្រះយេស៊ូដែលមានព្រះបន្ទូល ណែនាំឲ្យយើងភ្ញាក់ ណែនាំឲ្យយើងឆ្ងល់ **មូលហេតុអ្វីនំប៉័ងនេះក្លាយទៅជាព្រះកាយ? មូលហេតុអ្វីស្រានេះទៅជាព្រះលោហិត? មូលហេតុអ្វីព្រះយេស៊ូមានព្រះបន្ទូលថាសូមធ្វើដូច្នេះដើម្បីនឹករលឹកដល់ខ្ញុំ?**

ថ្ងៃនេះ យើងពោរពេញដោយអំណរសប្បាយដោយសារព្រះយេស៊ូបានធ្វើដំណើរជាមួយយើង នៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។ ថ្ងៃនេះយើងជាភ្ញៀវពិសេស ដោយសារយើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ព្រះអង្គចង់ឲ្យយើងរួមតុជាមួយព្រះអង្គដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ដើម្បីមើលឃើញស្នាដៃរបស់ព្រះយេស៊ូ កាយវិការរបស់ព្រះយេស៊ូ។ ថ្ងៃនេះ ព្រះយេស៊ូមានកាយវិការពិសេសសម្រាប់យើង យើងឃើញព្រះយេស៊ូដែលឈរឡើងហើយយក

ក្រមាក្រវ៉ាត់ចង្កេះ ក្រោយមកព្រះអង្គអង្គុយនៅមុខជើងខ្ញុំហើយចាប់ផ្ដើមលាងជើងឲ្យខ្ញុំ។ **មូលហេតុអ្វី ថ្ងៃនេះព្រះយេស៊ូដែលជាព្រះគ្រូ ព្រះយេស៊ូដែលជាព្រះអម្ចាស់លុតជង្គង់នៅមុខខ្ញុំដើម្បីលាងជើងឲ្យខ្ញុំ?** ប្រហែលខ្ញុំដូចលោកសិលា និងគ្រីស្ដទូតឯទៀតៗ ខ្ញុំឆ្ងល់ ខ្ញុំភ្ញាក់ ព្រះយេស៊ូចាប់ផ្ដើមលាងជើងខ្ញុំនិងមានព្រះបន្ទូលសម្រាប់ខ្ញុំនៅថ្ងៃនេះថា "**ខ្ញុំបានលាងជើងដល់ប្អូន សូមប្អូនយកចិត្តទុកដាក់ដើម្បីលាងជើងឲ្យគ្នាទៅវិញទៅមក ដូចខ្ញុំបានលាងជើងដល់បងប្អូនឯទៀតដែរ ខ្ញុំបានធ្វើជាគំរូសូមធ្វើតាមចុះ**"។ នេះជាព្រះបន្ទូលសម្រាប់ខ្ញុំថ្ងៃនេះ ព្រះយេស៊ូអញ្ជើញខ្ញុំឲ្យខ្ញុំលាងជើងដល់បងប្អូនឯទៀតៗ មានន័យថាព្រះយេស៊ូអញ្ជើញខ្ញុំឲ្យខ្ញុំបម្រើ ឲ្យខ្ញុំចេះមើលទុក្ខលំបាក អំណរសប្បាយ សេចក្ដីសង្ឃឹម សេចក្ដីត្រូវការរបស់បងប្អូនឯទៀតៗ និងខិតខំឆ្លើយតបដើម្បីខិតខំណែនាំឲ្យបងប្អូនឯទៀតៗមានសេចក្ដីសុខ និងមានអំណរសប្បាយ។ ថ្ងៃនេះ ព្រះយេស៊ូអញ្ជើញខ្ញុំឲ្យខ្ញុំទៅជាអ្នកបម្រើ យើងដឹងថានៅក្នុងសង្គមរបស់យើង យើងមិនចង់ធ្វើជាអ្នកបម្រើទេ យើងចង់ធ្វើជាមេ យើងចង់ធ្វើជាអ្នកដឹកនាំ...។ ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូមានគំនិតថ្មីនិងណែនាំឲ្យយើងទៅជាអ្នកបម្រើដូចព្រះអង្គបានបម្រើ ដូចព្រះយេស៊ូបានស្រឡាញ់ ដូចព្រះយេស៊ូបានលើកលែងទោស។

ថ្ងៃនេះជាថ្ងៃពិសេស សម្រាប់យើងជាគ្រីស្ដបរិស័ទ ជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ព្រះយេស៊ូមិនណែនាំឲ្យយើងអង្គុយមើលព្រះអង្គដោយស្ងៀមស្ងាត់ ព្រះយេស៊ូថ្ងៃនេះណែនាំឲ្យយើងទៅជាអ្នកបម្រើយ៉ាងសកម្ម។ អ្នកបម្រើដែលចេះមើលបងប្អូននៅជុំវិញ យើងត្រូវការគិតនៅក្នុងភូមិរបស់យើង **តើយើងត្រូវធ្វើអ្វីខ្លះសម្រាប់បងប្អូនឯទៀតៗ?** សម្រាប់កូនក្មេង សម្រាប់យុវជន សម្រាប់ស្ត្រីមេម៉ាយ សម្រាប់បងប្អូនក្រីក្រ សម្រាប់ចាស់ជរា... **តើខ្ញុំដែលជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ខ្ញុំបានធ្វើអ្វីខ្លះដើម្បីបម្រើគាត់ ដើម្បីលើកទឹកចិត្តគាត់ ដើម្បីផ្ដល់កម្លាំងកាយកម្លាំងចិត្តឲ្យគាត់?** ឲ្យយើងធ្វើតាមព្រះយេស៊ូ ព្រះយេស៊ូបានស្រឡាញ់ខ្ញុំ ព្រះយេស៊ូបានលើកលែងទោសឲ្យខ្ញុំ ព្រះយេស៊ូបានបម្រើខ្ញុំ។

អ្នកដែលរួមតុជាមួយព្រះយេស៊ូ មានក្រុមគ្រីស្ដទូត១២នាក់ក្នុងនោះមានលោកយ៉ូដាស់អ៊ីស្ការីយ៉ូត ដែលបានក្បត់។ នៅពេលព្រះយេស៊ូបានលាងជើងហើយ លោកយ៉ូដាស់អ៊ីស្ការីយ៉ូតបានចេញពីបន្ទប់ដើម្បីត្រៀមខ្លួនក្បត់ព្រះយេស៊ូ។ ព្រះយេស៊ូនៅជាមួយ១១នាក់ ពេលនោះព្រះយេស៊ូបានប្រទានធម្មវិន័យរបស់ព្រះអង្គឲ្យក្រុមគ្រីស្ដទូតនៅពេលហ្នឹង ធម្មវិន័យនោះគឺ "**ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា**"។ យប់នេះ យើងជាក្រុមគ្រីស្ដទូត យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ព្រះយេស៊ូមិនណែនាំឲ្យយើងបម្រើតែបងប្អូនឯទៀតៗ ប៉ុន្តែព្រះអង្គមានព្រះបន្ទូលមួយពិសេសសម្រាប់យើង "**យប់នេះឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅ**

**មកដូចព្រះយេស៊ូបានស្រឡាញ់យើង**"។ យប់នេះ យើងបានឃើញយ៉ាងជាក់ស្តែងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគឺ ព្រះយេស៊ូបានណែនាំឲ្យយើងទទួលរូបកាយនិងព្រះលោហិតរបស់ព្រះអង្គផ្ទាល់។ ថ្ងៃស្អែក ពេលព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាងមានន័យថាសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ មិនមែនតែព្រះបន្ទូលដែលចេញពីបបូរមាត់របស់ព្រះអង្គ ប៉ុន្តែជាជីវិតរបស់ព្រះអង្គ។ ព្រះយេស៊ូប្រទានជីវិត ដើម្បីឲ្យយើងមានសេចក្តីសុខ ដូច្នេះយប់នេះឲ្យយើងត្រៀមខ្លួនពេលយើងអធិដ្ឋាននៅមុខព្រះកាយឲ្យយើងចូលរួមជាមួយព្រះយេស៊ូ នៅក្នុងការបម្រើ និងនៅក្នុងការស្រឡាញ់។ សូមស្រឡាញ់ បម្រើ និងអធិដ្ឋាន ព្រះយេស៊ូណែនាំឲ្យយើងអធិដ្ឋានកំដរព្រះយេស៊ូ ដើម្បីធ្វើដំណើរជាមួយព្រះអង្គរហូតដល់ព្រះយេស៊ូឡើងលើឈើឆ្កាង និងសោយទិវង្គត។

យើងនៅស្ងៀមស្ងាត់ដើម្បីនឹកឃើញថា **តើខ្ញុំធ្វើអ្វីខ្លះដើម្បីបម្រើ? តើខ្ញុំធ្វើអ្វីខ្លះដើម្បីស្រឡាញ់? តើខ្ញុំធ្វើដូចម្តេចដើម្បីយកចិត្តទុកដាក់អធិដ្ឋាននិងភ្ជាប់ជាមួយព្រះយេស៊ូ?** ដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គទៅដល់បងប្អូនឯទៀតៗជានិច្ច។ អាម៉ែន៕